# សុន្ទរកថារបស់

ឯកឧត្តម **ចាន់ សារុន្ទ** អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
ថ្លែងក្នុងពិធីបើកកិច្ចប្រជុំពិគ្រោះយោបល់ ស្តីពីគំរូមិត្តកសិករ
នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
(រាជធានីភ្នំពេញ,ថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២១)

*សូមគោរព*

- *គណៈអធិបតី*
- *លោកជំទាវ ឯកឧត្តម អស់លោក លោកស្រី និងនាងកញ្ញាទាំងអស់ជាទីមេត្រី !*

ថ្ងៃនេះខ្ញុំមានមានកិត្តិយសនិងសេចក្តីសោមនស្សរីករាយ ដោយបានមកចូលរួមជាអធិបតីក្នុងឱកាសបើកកិច្ចប្រជុំពិគ្រោះយោបល់ ស្តីពីគំរូមិត្តកសិករនាពេលនេះ។ ក្នុងនាមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនិងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមថ្លែងអំណរគុណនិងស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមានចូលរួមរបស់សមាជិកសមាជិកាទាំងមូល ដែលបានចូលរួមតាមរយៈកិច្ចប្រជុំពីចម្ងាយនាពេលនេះ។ ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមសំដែងការកោតសរសើរ ចំពោះការខិតខំរៀបចំឱ្យមានកិច្ចប្រជុំពិគ្រោះយោបល់នេះឡើងដោយនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទក្រោមកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយអង្គការស្វីសខនថាក់ ក្នុងអំឡុងពេលយើងទាំងអស់គ្នាកំពុងមានការប្រឈមជាមួយជំងឺឆ្លងកូវីដ១៩ នាពេលបច្ចុប្បន្ននៅកម្ពុជា។

*អង្គប្រជុំជាទីមេត្រី!*

ដូចយើងទាំងអស់គ្នាបានដឹងហើយថា ការងារផ្សព្វផ្សាយ គឺជាកត្តាគន្លឹះនិងជាស្ពានសម្រាប់បញ្ជូនព័ត៌មានឬផ្ទេរបច្ចេកទេសនិងបច្ចេកវិទ្យាពីអង្គភាពជំនាញពាក់ព័ន្ធទៅអ្នកប្រើប្រាស់ ដែលជាផលិតករកសិកម្ម ជាពិសេសជូនដល់ប្រជាកសិករបានទាន់ពេលវេលានិងសមស្របទៅតាមតម្រូវការរបស់ពួកគេ។ ហេតុដូចនេះហើយបានជារាជរដ្ឋាភិបាលកម្ពុជា បានសម្រេចប្រែក្លាយនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្មមកជានាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចំណុះឱ្យអគ្គលេខាធិការដ្ឋាននៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទវិញ។

ជារួមការងារផ្សព្វផ្សាយបច្ចេកទេសកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺពាក់ព័ន្ធសកម្មភាពសំខាន់ៗចំនួន៣គឺ:

ទី(១) <u>ការផ្សព្វផ្សាយតាមរយៈការបណ្តុះបណ្តាល</u> ការសិក្សានិងវិភាគប្រព័ន្ធកសិកម្មនិងសេដ្ឋកិច្ចគ្រួសារកសិករ ការអនុវត្តជាក់ស្តែងនៅទីវាល សាលារៀនស្រែកសិករ ការធ្វើស្រែបង្ហាញ ទិវាស្រែ និងទស្សនៈកិច្ចសិក្សា

ទី(២) <u>ការផ្សព្វផ្សាយតាមរយៈប្រព័ន្ធសាធារណៈ</u> បណ្តាញទំនាក់ទំនងសង្គម គេហទំព័រផ្សព្វផ្សាយកសិកម្ម មជ្ឈមណ្ឌលបណ្តុំព័ត៌មានផ្សព្វផ្សាយកសិកម្ម សេវាផ្តល់ព័ត៌មានបច្ចេកទេសកសិកម្មដល់កសិករ និងអតិថិជន (Call Center) ពិព័រណ៍ផលិតផលកសិកម្ម និងវេទិកាសាធារណៈ និង

ទី(៣) <u>ការផ្សព្វផ្សាយតាមរយៈការបោះពុម្ព</u> និងចែកចាយឯកសារបច្ចេកទេសកសិកម្ម។

ដើម្បីឱ្យសកម្មភាពសំខាន់ៗចំនួន៣ខាងលើ អាចប្រព្រឹត្តទៅបានរលូនប្រកបដោយជោគជ័យ និងមាននិរន្តរភាពនោះ លុះត្រាតែមានការចូលរួមរបស់វិស័យឯកជនក៏ដូចជាដៃគូអភិវឌ្ឍន៍ ដែលជាជាកត្តាចាំបាច់មិនអាចខ្វះបានដោយសារវិស័យសាធារណៈ (រដ្ឋ) មិនអាចគ្រប់ដណ្តប់លើសេវាផ្សព្វផ្សាយនិងការផ្តួចផ្តើមគំនិតថ្មីៗ (Innovation) បានទាំងអស់នោះទេ។ ទន្ទឹមនេះ តាមរយៈបទពិសោធន៍នៃការអនុវត្តគម្រោងរួមគ្នាកន្លងមកមួយចំនួនពាក់ព័ន្ធសកម្មភាពកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាព ដោយនាយកដ្ឋានគ្រប់គ្រងធនធានដីកសិកម្ម នាយកដ្ឋានវិស្វកម្មកសិកម្ម មជ្ឈមណ្ឌលស្រាវជ្រាវកសិកម្មបារាំងសម្រាប់ការអភិវឌ្ឍអន្តរជាតិ (CIRAD) អង្គការស្វីសខនថាក់ (Swisscontact) និងមជ្ឈមណ្ឌលឧត្តមភាពប្រពលវប្បកម្មកសិកម្មនិរន្តរភាពនិងអាហាររូបត្ថម្ភ (CE-SAIN) ដោយមានការចូលរួមពីផ្នែកឯកជនជាអ្នកផ្គត់ផ្គង់សេវាកម្មគ្រឿងយន្តកសិកម្ម និងឧបករណ៍កសិកម្ម និងគ្រាប់ពូជដំណាំគម្របដី ពីសហគមន៍កសិកម្ម និងពីប្រជាកសិករ ឃើញថា ប្រសិទ្ធភាពនៃការផ្សព្វផ្សាយមានលក្ខណៈល្អប្រសើរនិងមានភាពប្រទាក់ក្រឡាគ្នាគ្រប់តួអង្គពាក់ព័ន្ធទាំងអស់។ ដូចនេះ វាគឺជាការវិវឌ្ឍន៍ថ្មីមួយ ដែលឈានដល់ការបង្កើតឱ្យមានគម្រូកែលំអរថ្មីមួយ មានឈ្មោះថា "មិត្តកសិករ" ដែលយើងទាំងអស់គ្នាមកប្រជុំពិភាក្សាគ្នានៅថ្ងៃនេះ ដើម្បីឈានទៅដល់ការអនុវត្តរួមគ្នានាពេលអនាគត ទោះបីជាគម្រូមិត្តកសិករនេះ នៅមិនទាន់បានដាក់ឱ្យដំណើរការជាផ្លូវការនៅឡើយ។

*អង្គពិធីជាទីមេត្រី!*

ខ្ញុំសង្ឃឹមនិងជឿជាក់ថា តាមរយៈកិច្ចប្រជុំពិគ្រោះយោបល់ ស្តីពីគំរូមិត្តកសិករនាពេលនេះ នឹងធ្វើឱ្យមានការស្វែងយល់នូវប្រព័ន្ធផ្សព្វផ្សាយថ្មីមួយ ដែលអាចសហការគ្នានិងទទួលយកបានទាំងអស់គ្នាពីគ្រប់តួអង្គពាក់ព័ន្ធទាំងអស់។ ខ្ញុំស្នើសុំឱ្យមានការយកចិត្តទុកដាក់និងពិភាក្សាគ្នា រួមគ្នាសហការបែបណា ចៀសវាងធ្វើសកម្មភាពនេះបន្តិចធ្វើសកម្មភាពនោះបន្តិច "ដាច់ដោយដុំ" តាមរៀងៗខ្លួនរបស់អង្គភាពនីមួយៗ។ ត្រូវជួយដល់ផលិតករ ក៏ដូចជាប្រជាកសិករក្នុងខ្សែច្រវាក់ផលិតកម្មកសិកម្មនីមួយៗពីដើមទីរហូតដល់ចុងទី (a full value change) ឱ្យមានថេររហូត ដើម្បីឱ្យមានការចាប់អារម្មណ៍និងអាចទាក់ទាញទីផ្សារកសិកម្មបានច្រើននិងមាននិរន្តរភាព តាមអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនាពេលកន្លងមក។ ឧទា តើរួមគ្នាអនុវត្តការងារចាប់ពីការរៀបចំដី ការដាំដុះ ការប្រមូលផល និងការកែច្នៃវេចខ្ចប់បែបណា? តួអង្គណាជាអ្នកធ្វើសកម្មភាព ជាអ្នកគាំទ្រ ជាអ្នកសម្របសម្រួល និងជាអ្នកចេញចំណាយ។ល។

ជាទីបញ្ចប់ ខ្ញុំសូមប្រសិទ្ធិពរជ័យ សិរីមង្គល វិបុលសុខ ជូនចំពោះលោកជំទាវ ឯកឧត្តម អស់លោកលោកស្រី អ្នកនាងកញ្ញា សូមប្រកបដោយពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ និងសូមប្រកាសបើកកិច្ចប្រជុំពិគ្រោះយោបល់ ស្តីពីគំរូមិត្តកសិករ ចាប់ពីពេលនេះតទៅ។

*សូមអរគុណ!*